## មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0181**

# សម្ភាសន៍ជាមួយឈ្មោះ ទុយ សុផល ភេទស្រី អាយុ៥១ឆ្នាំ
# មុខងារនៅសម័យខ្មែរក្រហមៈ "កងចល័តនៅត្រពាំងថ្ម"
# សព្វថ្ងៃរស់នៅភូមិដូនជ្រែង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១
# សម្ភាសន៍ដោយៈ ហ៊ិន សុធានី
# ០០:៥៨:២៨
# ២៦ទំព័រ

ធានី ៖ ថ្ងៃនឹង ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១ ។ ខ្ញុំឈ្មោះ ធានី ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយពួកខ្ញុំចុះមកនេះ ចង់ស្រាវជ្រាវទាក់ទងប្រវត្តិអ្នកដែលធ្វើការនៅសម័យបដិវត្តដែលមីងនិយាយមិញ ។ រឿងរ៉ាវមីងប្រាប់ពួកខ្ញុំទាំងប៉ុន្មាន ពួកខ្ញុំសុំយកមកចុះក្នុងទស្សនាវដ្ដី ក៏ដូចជាសម្រាប់អ្នកស្រាវជ្រាវផ្សេងៗ គាត់ដឹងបានរៀនសូត្រ ជាពិសេសសម្រាប់ឲ្យក្មេងជំនាន់ក្រោយយើង បានយល់ដឹងពីសម័យនឹង ថាតើមានការលំបាកយ៉ាងម៉េច ដូចថាការរស់នៅរបស់គាត់ ប្រជាជននៅនឹងយ៉ាងម៉េច ។

សុផល ៖ មុននៅលើកទំនប់ពេលដែលដើរចល័តនឹង ។

ធានី ៖ យ៉ាងម៉េចទៅ?

សុផល ៖ គេឲ្យនៅ អាទំនប់យើងទំនប់ពីស្រែះទៅកំបោរ នាំគ្នាលើកទៅ ។ ដល់លើកចប់ទៅគេឲ្យទៅ ភ្នំកងវ៉ៗខាងនេះ ហៅភ្នំបាក់ ។ នៅភ្នំបាក់គេឲ្យនាំគ្នានៅកាប់ឆ្ការ ដូចថាយើងកាប់ឆ្ការព្រៃ ដាំកប្បាស ដាំអី ពីសម័យនោះ យប់ក៏ធ្វើដែរកាលនោះ ។

ធានី ៖ ម៉េចទៀតមីង?

សុផល ៖ ទៅក៏គេឲ្យមកនៅត្រពាំងថ្មនេះវិញ ។ ត្រពាំងថ្ម គេឲ្យលើកទំនប់ ជីកប្រឡាយទៅឯងបានៗ គ្រួសារមុននោះ ដល់បានទៅគេឲ្យមកនៅភូមិចក្រី នៅជាមួយប្ដី ។ ដល់នៅទៅបានត្រឡប់មកភូមិយើងវិញ ភូមិដូនជ្រែង ។

ធានី ៖ ម៉េចទៀត?

សុផល ៖ បេះក្លេច ។ មកនៅភូមិចក្រីហើយ មកនៅភូមិដូនជ្រែងហើយមានស្អីទៀត ចប់ហើយ ។

ធានី ៖ កាលនឹងមីងដឹងថា បដិវត្តនឹងជាស្អី?

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

សុផល ៖ សម័យបដិវត្តថាបដិវត្តនឹងគេទៅ ។

ធានី ៖ កាលនឹងមីងបានចូលរួមបដិវត្តនឹងអត់?

សុផល ៖ ខ្ញុំមានធ្វើអី មានតែលើកទំនប់ជីកប្រឡាយធម្មតា ស្ទូងដក គេឲ្យធ្វើអីធ្វើនោះទៅ ។

ធានី ៖ កាលសម័យបដិវត្តនោះ ម៉េចមីងដឹងថាគេហៅសម័យនឹងសម័យបដិវត្ត?

សុផល ៖ ចេះតែថាតាមគេទៅ មិនដឹងអីទេ ។

ធានី ៖ កាលនោះមីងអាយុប៉ុន្មាន សម័យបដិវត្ត?

សុផល ៖ អាយុចាប់ផ្ដើមមកដល់អាយុ១៥ ។

ធានី ៖ ចុះឥឡូវ?

សុផល ៖ ៥១ហើយ ។

ធានី ៖ ចុះមុនសម័យបដិវត្ត មានសម័យអីទៀត ដែលចាំទេ?

សុផល ៖ មិនសូវដែលដឹង កាលនោះនៅក្មេងដែរ អាយុ១២-១៣ឆ្នាំ ។

ធានី ៖ កាលនឹងអាយុ១២-១៣ឆ្នាំ អត់ចាំសម័យអីទេ? តែគ្រាន់ដឹងពីអាយុ១៥ទៅ សម័យបដិវត្ត?

សុផល ៖ នោះហើយ ។

ធានី ៖ គ្រាន់ដឹងថាអាយុ១៥ឆ្នាំទៅសម័យបដិវត្ត?

សុផល ៖ នោះហើយ ។

ធានី ៖ កាលនោះគេធ្វើម៉េចខ្លះ ពេលមីងអាយុ១៥ឆ្នាំ កាលនឹងគេមានធ្វើអីខ្លះ ដូចថាសម័យបដិវត្តនឹងសម័យយ៉ាងម៉េច
ហើយគេប្រាប់យ៉ាងម៉េចបានដឹងថាសម័យនឹងសម័យបដិវត្ត?

សុផល ៖ ដឹង បដិវត្តក៏បដិវត្តនឹងគេទៅ ។

ធានី ៖ បដិវត្តនឹងគេធ្វើម៉េចខ្លះ?

សុផល ៖ នាំគ្នាទៅជីកប្រឡាយ លើកទំនប់ ។ មុនដំបូងលើកទំនប់ពីស្រែះទៅកំបោរ ។ ចប់ពីនោះទៅគេឲ្យទៅ ។

ធានី ៖ អ្នកណាគេចាត់តាំងឲ្យមីងលើកទំនប់អីនឹង ពីស្រែះទៅកំបោរ? អ្នកណាគេអ្នកចាត់តាំងឲ្យមីងលើក?

សុផល ៖ ប្រធានអ្នកណាខ្លះច្រើន ដល់យូរទៅ ចង់ភ្លេចប្រធានអស់ ។

ធានី ៖ រកនឹកមើលមីង អ្នកណាគេនៅភូមិយើងដែរ?

សុផល ៖ ភ្លេចប្រធានអស់ហើយ ពួកអារុំ ពួក ។

ធានី ៖ រុំ គាត់ជាអ្នកណាគេ?

សុផល ៖ អារុំ នៅព្រះនេត្រព្រះ ប៉ុនសព្វថ្ងៃមិននៅផ្ទះទេ សព្វថ្ងៃមិនដឹងទៅខាងណាទេ ។

ធានី ៖ បងរុំនឹង គាត់មានមុខងារជាអីគេ?

សុផល ៖ គាត់ប្រធានកង ។

ធានី ៖ ប្រធានកងអីគេ?

សុផល ៖ ប្រធានកងតូច ប្រធានកងធំទេ ខ្ញុំភ្លេចអស់ហើយ ប្រធានកងវាមានច្រើន មានកងតូច កងធំ ។ ចែម្នាក់ ប៉ុនងាប់បាត់ហើយ ឈ្មោះ ចែ វ័ន្ត ។

ធានី ៖ ចែ វ័ន្ត ប្រធានកងរបស់មីងដែរ?

សុផល ៖ មិនមែនប្រធានកងរបស់ខ្ញុំទេ តែគ្រាន់ថានៅជាមួយគ្នា ដូចថាកងគេផ្សេងៗណា ។ ខ្ញុំភ្លេចអស់ហើយ ឈ្មោះបងសល់ បងអី ដឹងទៅខាងណាខាងណែ វាយូរដែរ ។

ធានី ៖ ចឹងចង់សួរថា មីងអ្នកស្រុកដូនជ្រៃ ម៉េចបានមីងទៅកងចល័តលើកទំនប់នៅស្រះ នៅកំបោរវិញ ព្រោះភូមិដូនជ្រៃង មិនមែនភូមិកំបោរ?

សុផល ៖ គេឲ្យទៅលើកទៅ ហៅទៅនារីហៅយុវជនរើសទៅច្រើន កាលនោះភ្លេចអស់ហើយ ខ្លះងាប់ ខ្លះ ច្រើនអ្នកងាប់ ទៅក៏ងាប់ ធ្វើប្រធានគេសម្លាប់ចោល ។

ធានី ៖ អូ! អ្នកខ្លះធ្វើប្រធានហើយគេសម្លាប់ចោលដែរ អ្នកភូមិយើង?

សុផល ៖ នោះហើយ ភូមិនេះឯង ពួកមីស្រេះ ងាប់អស់ហើយ មីវិត ។

ធានី ៖ តែវិតនឹង គាត់ជាប្រធាន?

សុផល ៖ ប្រធាន ទំនប់ត្រពាំងថ្មដឹង ។

ធានី ៖ វិតនឹង អ្នកស្រុកយើងដែរ?

សុផល ៖ អ្នកនៅដូនជ្រៃង ២នាក់បងប្អូន វិត, ស្រេះ បងប្អូនបង្កើតធ្វើប្រធានទាំងអស់គ្នា ។

ធានី ៖ ប្រធានអីគេ ប្រធានកងនារី?

សុផល ៖ ប្រធានកងយុវជន សុទ្ធតែយុវជន ។

ធានី ៖ ប៉ុន្មាននាក់?

សុផល ៖ ២នាក់ ។

ធានី ៖ ចង់និយាយថាប្រធានកងយុវជននឹង មានប៉ុន្មាននាក់ កងគាត់ឈ្មោះកងអី?

សុផល ៖ អូ! ចំណាំមិនបានទេ ។

ធានី ៖ ចុះប្រធានកងមីង អ្នកណាគេ?

សុផល ៖ ដូចចង់ភ្លេចទៀត កាលនោះ ខ្ញុំខួរក្បាលដូចជាមិនសូវល្អ មិនសូវចាំ ។

ធានី ៖ ចឹងពេលមីងទៅធ្វើការនៅកងចល័តនឹង ចុះមីងដឹងថានៅភូមិយើង អ្នកណាគេអ្នកនៅគណៈស្រុកគណៈឃុំភូមិអីស្គាល់ទេ?

សុផល ៖ ប្រធានភូមិ ។

ធានី ៖ ហ្នឹងហើយ ដែលចាត់តាំងឲ្យមីងទៅ?

សុផល ៖ ខ្ញុំភ្លេចអស់ហើយ កាលនោះខ្ញុំនៅក្មេងដែរ វាយូរគ្រាន់ កាន់នោះវាអាយុ១៤-១៥ ទើបនឹងធំ ទៅតាមគេ ដូចថាកាលនោះយើងចង់ដែរ ។ កាលនៅអត់ទាន់ចូលមក មានដឹងអីពុចថា គេថាទៅលើកទំនប់ដឹកប្រឡាយ តាមពិតអាយុយើងតិចទេ ទៅតាមគេ ។

ធានី ៖ ចឹងអាយុប៉ុន្មាន បានគេឲ្យទៅលើកទំនប់ ដឹកប្រឡាយ?

សុផល ៖ អាយុ១៧ ១៨អីទៅ ដូចថាយើងមនុស្សធំដែរ ធំល្បឿនក៏ដូចថារូបយើងធំដែរទៅនឹងគេទៅ ពួកនោះដូចថាខួរក្បាលគេល្អ ខ្ញុំអត់សូវចាំទេ ។

ធានី ៖ បន្ទាប់ពីមីងថាទៅដឹកប្រឡាយនៅណា មីងថាទៅកំបោរនឹងលើកទំនប់ ដឹកប្រឡាយដែរ?

សុផល ៖ លើកទំនប់ ដឹកប្រឡាយ ។

ធានី ៖ ពេលទៅដឹកទំនប់នឹងម៉េចដែរ ការហូបចុកអី ការស្នាក់នៅអីម៉េចទៅ?

សុផល ៖ ស្នាក់នៅគេធ្វើខ្ទម នៅនឹងរោងគេ មានអីរោងយើងធម្មតារោង ។

ធានី ៖ មីងថាមីងទៅលើកទំនប់នៅត្រពាំងថ្មនឹង លើកនៅពេលណា មីងរកនឹកមើល កាលនោះមីងអាយុប៉ុន្មាន?

សុផល ៖ ១៦-១៧ កាលនោះបានប្ដីហើយ ១៧ ។

ធានី ៖ អាយុ១៧ មីងទៅលើកទំនប់ត្រពាំងថ្មនឹង?

សុផល ៖ ចាំ!

ធានី ៖ ហើយមីងលើកបានប៉ុន្មានឆ្នាំ លើកបានប៉ុន្មានខែ?

សុផល ៖ ដឹងបានប៉ុន្មានខែទេ ភ្លេចហើយ លើកបានលើក ដល់បានប្ដីមកក៏មកវិញ មកនៅស្រុក ។

ធានី ៖ រកនឹកមើលមីង លើកដូចបានប៉ុន្មានខែ បានមានគ្រួសារហើយត្រឡប់មកវិញ?

សុផល ៖ ដឹងបានប៉ុន្មាន ។

ធានី ៖ ម៉ាខែ ២ខែ ចូលវស្សាទៅ កាលនឹង? ដល់ពេលមីងលើកទំនប់នៅត្រពាំងថ្មនឹង កាលនឹងទំនប់នឹងគេធ្វើហើយខ្លះនៅ?

សុផល ៖ ទំនប់នោះ កាលនោះខ្ញុំលើកមិនទាន់រួច កាលនឹងនៅ ។

ធានី ៖ ចឹងមីងមកដំបូង កាលមុនៗមីងគេធ្វើហើយ គ្រាន់មីងមកបន្តទៀត ឬក៏យ៉ាងម៉េច?

សុផល ៖ កាលមកមុនៗមិនដែលបានទៅរហូត មិនដឹងថាគេលើករួចមិនរួច សព្វថ្ងៃមិនដែលបានទៅឃើញ ។

ធានី ៖ មិនមែនទេ ចង់និយាយថា កាលសម័យនឹង សម័យបដិវត្តនឹង ពេលដែលមីងទៅលើកទំនប់ នៅត្រពាំងថ្មនឹង ពេលទៅដល់នឹង ឃើញទំនប់នឹងគេកំពុងតែលើក?

សុផល ៖ ហ៊ឺ! ទៅមុនដំបូង ។

ធានី ៖ ទៅដល់ម៉េច?

សុផល ៖ ទៅដល់គេវាស់វែងលើកទៅ ។

ធានី ៖ កាលនឹងមានរៀងជាទំនប់នៅ មានដើងអីនៅ?

សុផល ៖ អត់ទេ ធ្វើជាទំនប់ចាស់ពីដើមដែរ ដូចថាមិនមានវាទំនប់ធំទេណា ដូចថាមានថ្មបាយក្រៀមថ្មអីគេនោះ ។ ដូចថាទំនប់ ទំនុំចាស់ពីដើម វាមិនមានទំនប់នេះទេ គ្រាន់តែដូចថាគេមានស្ពាន មើលទៅមានស្ពានបាយក្រៀម ស្ពានចាស់ពីដើម មុនយើងលើកទំនប់ទៀត ។

ធានី ៖ ចឹងមីងមិនមែនអ្នកនៅជាមួយគាត់?

សុផល ៖ បាននៅជាមួយគាត់ ។ គាត់ដូចថាចាស់ជាងយើងទៅ គាត់ដឹង គាត់ប្រធាននោះ ។

ធានី ៖ គាត់ប្រធានមីង?

សុផល ៖ ចា៎! គាត់ប្រធានកាន់កាប់ចុះពីតាវ៉ាល់មក ។

ធានី ៖ តាឈួងនេះ?

សុផល ៖ ចា៎!

ធានី ៖ ចុះមីងស្គាល់តាវ៉ាល់?

សុផល ៖ តាវ៉ាល់នេះថីមិនស្គាល់ៗ បានគ្រាន់តែស្គាល់ៗ ។

ធានី ៖ តាវ៉ាល់នឹងជាអ្នកណាគេ?

សុផល ៖ តាវ៉ាល់នឹង បដិវត្តមិញ គេនេះធំបដិវត្តនេះឯង តាវ៉ាល់នឹង ។

ធានី ៖ មេធំយ៉ាងម៉េច ដឹងគាត់ជាអ្នកណា?

សុផល ៖ គាត់ស្អីទេ ប្រធានបញ្ជាឲ្យលើកទំនប់អីណា ។

ធានី ៖ លើកទំនប់នៅតែត្រពាំងថ្មនឹង ឬក៏លើកទំនប់នៅកន្លែងផ្សេងទៀត?

សុផល ៖ ត្រង់ណាក៏គាត់ដែរ គាត់ប្រធានទាំងអស់ គាត់នេះឯងពីលើគេ ដូចថាឲ្យគេលើកត្រង់នេះត្រង់នោះ ។

ធានី ៖ ចុះបន្ទាប់ពីតាវ៉ាល់មក?

សុផល ៖ គ្នាវាច្រើន មិនមានតែគេទេ មានអ្នកផ្សេងទៀត ។

ធានី ៖ អ្នកណាគេទៀត?

សុផល ៖ ចំណាំមិនបានទេ ។

ធានី ៖ អត់ចាំឈ្មោះគាត់ទៀតទេ?

សុផល ៖ ហ្នឹងហើយ អត់ចាំទេ ។

ធានី ៖ ចឹងក្រៅពីនឹង មីងធ្វើស្អីគេ?

សុផល ៖ ខ្ញុំធ្វើកូនក្រុមគេ គេឲ្យលើកអីខ្ញុំទៅលើកនោះ ។

ធានី ៖ កូនក្រុមអីគេ?

សុផល ៖ ក្នុងម៉ាក្រុមគេមាន១០នាក់ ឲ្យយើងធ្វើដល់ពេលយើងលើកទៅគេវាស់ដីឲ្យយើងលើកទៅគ្នា១០នាក់ គេវាស់ចែកគ្នា ។

ធានី ៖ ចឹងអ្នកណាគេធ្វើមេក្រុមរបស់មីង?

សុផល ៖ យូរណាស់ហើយ ខ្ញុំភ្លេចអស់ចាំមិនបានទេ ។

ធានី ៖ ធម្មតាម៉ាក្រុមចឹង មានតាមពួក?

សុផល ៖ វាភ្លេចគ្នាអស់ហើយ ។

ធានី ៖ ដូចថាម៉ាក្រុមចឹង មានប៉ុន្មានពួក?

សុផល ៖ វាមានតាមពួក ម៉ាពួកមាន៣នាក់ ។

ធានី ៖ ចុះដល់ពេលប្រធានក្រុមធ្វើអីគេ បើម៉ាក្រុមមាន៣នាក់?

សុផល ៖ ធ្វើទាំងអស់តែគ្នា លើកទំនប់ដូចតែគ្នា ។

ធានី ៖ ព្រោះមីងថាម៉ាក្រុមមាន៣ពួក ម៉ាពួកមាន៣នាក់ ទាំងអស់១០នាក់ នៅសល់ម្នាក់ៗធ្វើអីគេ?

សុផល ៖ លើកដូចតែគ្នា គេវាស់ដីលើកដូចតែគ្នា ៣០នាក់ ១០នាក់ លើកទាំងអស់គ្នា ។

ធានី ៖ ចឹងគេវាស់នឹងសម្រាប់ម៉ាក្រុម គេវាស់ចែកគ្នា?

សុផល ៖ គេវាស់ម៉ែត្រគីបឲ្យលើក ។

ធានី ៖ ប៉ុន្មានម៉ែត្រ?

សុផល ៖ ខ្លះស្រេចតែនឹងយើង ដូចថាខ្លះគេកម្លាំង កាលនោះដូចថាមនុស្សដោរដែរនឹង មនុស្សដោរ គេឲ្យលើកខ្លាំង ដូចថាខំចេះតែខំទៅ បើដូចខ្ញុំអីលើកតែម៉ាម៉ែត្រគីបលើកមិនរួចផង ។

ធានី ៖ មីងលើកតែម៉ាម៉ែត្រគីបទេ?

សុផល ៖ នោះហើយខ្លះគេលើក៣ម៉ែត្រគីប បើសិនមនុស្សប្រុសវិញ បើមនុស្សស្រីខ្លះគេខ្លាំងទៅ ម៉ាម៉ែត្រគីបកន្លះអីទៅលើក ។

ធានី ៖ ចឹងនៅក្រុមមីងលើកម៉ាម៉ែត្រគីបទាំងអស់គ្នា?

សុផល ៖ លើកដូចតែគ្នា ។

ធានី ៖ ម៉ាម៉ែត្រគីបទាំងអស់គ្នា?

សុផល ៖ ហ្នឹងហើយ
គេចាត់ឲ្យយើងលើកទៅក្នុងម៉ាប្រឡោះមុខយើងចេះម៉ាក្រុមយើងចេះវាស់លើក ទៅ ទទឹងបណ្តោយប៉ុន្មានម៉ែត្រ ។

ធានី ៖ ទទឹង បណ្តោយប៉ុន្មាន?

សុផល ៖ អូ! ចាំណាំមិនបានទេ យូរណាស់ហើយ ទំនប់នោះវាធំដូចថាយើងយូរទៅវាមិនបានចាំ ។

ធានី ៖ ចឹងកាលមីងនៅម៉ាម៉ែត្រគីបប៉ុនណាទៅ?

សុផល ៖ ម៉ាម៉ែត្រគីបនោះវាមានទទឹងម៉ាម៉ែត្រ បណ្តោយម៉ាម៉ែត្រ ។

ធានី ៖ ចុះជំរៅវា?

សុផល ៖ ជំរៅម៉ាម៉ែត្រ ។

ធានី ៖ ហើយក្រុមមីងលើកចឹងទាំងអស់គ្នាហើយម៉េច?

សុផល ៖ លើកទាំងអស់គ្នា ។

ធានី ៖ ចុះមីងថាអ្នកខ្លះលើកបានម៉ាម៉ែត្រកន្លះ?

សុផល ៖ នាំគ្នាលើកមិនបាន យើងចេះតែខំ ។

ធានី ៖ ខំយ៉ាងម៉េច?

សុផល ៖ ខំឲ្យលើកឲ្យរួច គេកំណត់ឲ្យយើងលើក ដូចថាដាក់ម៉ាម៉ែត្រគេឲ្យយើងលើកឲ្យរួចទៅ យើងខំឲ្យរួចទៅ បើខំមិនរួចទេហូបបាយរួចទៅលើកទៀតទៅ ។

ធានី ៖ ចឹងមានអ្នកខ្លះដែលគេខំម៉ាម៉ែត្រនឹងហើយ គេហូបបាយ គេសម្រាកទៅ?

សុផល ៖ សម្រាកទៅ ។

ធានី ៖ ចុះមីង?

សុផល ៖ បើយើងទំលើកមិនរួច យើងមិនរួចទៅទៀត ។

ធានី ៖ ចឹងមីងដូចថាមីងធ្វើការពីពេលណាដល់ពេលណា?

សុផល ៖ មិនចាំទេ ភ្លេចអស់ហើយ ។

ធានី ៖ ដូចថាពេលព្រឹកធ្វើពីស្មានណាទៅ ពេលថ្ងៃធ្វើពេលណា យប់ឡើងមីងមានធ្វើទៀតអត់?

សុផល ៖ ព្រឹកឡើង ដែលមានម៉ោងមានអីទេ ដឹងថាព្រឹកឡើងក្រោកឡើងទៅលើកទៅ ថ្ងៃឡើងស៊ីបាយ ហូបបាយ ថ្ងៃឡើងហូបបាយរួចចុះទៅទៀតទៅ ។

ធានី ៖ ចឹងព្រឹកឡើងហូបបាយ ម៉ោងប៉ុន្មាន?

សុផល ៖ ក្រោកស៊ីពីព្រឹកទៅ ម៉ោង៦-៧នោះឯង ។

ធានី ៖ ចឹងមីងធ្វើការម៉ោង៦-៧ព្រឹក?

សុផល ៖ អឺ!

ធានី ៖ ចង់និយាយថាមីងក្រោកទៅធ្វើការជីកដីនឹង តាំងពីពេលណា? ក្រោកតាំងពីមាន់រងាវមុន មាន់រងាវ ឬយ៉ាងម៉េច?

សុផល ៖ ភ្លឺ ។

ធានី ៖ ភ្លឺហើយរហូតដល់ម៉ោងប៉ុន្មាន?

សុផល ៖ ម៉ោង១១ ភ្លេចហើយ ។

ធានី ៖ ហើយបន្ទាប់មកទៀត ដល់ម៉ោងប៉ុន្មានទៀត បានចាប់ធ្វើ?

សុផល ៖ មិនមានកំណត់ម៉ោង ស្រេចយើងចុះម៉ោង១ម៉ោង២ ដូចថារួចចេះតែលើក ខ្លះចេះទំលើកឲ្យរួច ។

ធានី ៖ រហូតដល់ពេលណាមីងសម្រាក ឈប់លើកដីលើកអីនឹង?

សុផល ៖ បានប្តីក៏មកផ្ទះឈប់លើកហើយ ។

ធានី ៖ ចឹងមីងអត់មានធ្លាប់ធ្វើការ លើកទំនប់ពេលយប់ណា?

សុផល ៖ អត់ទេ ។

ធានី ៖ លើកដល់ពេលល្ងាចសម្រាកទៅ?

សុផល ៖ ចាំ! ដោយអាខ្លះដូចថាពីសម័យនោះ គេហៅកងករណីៗដូចថាធ្វើការទៅ យើងធ្វើការអត់ហើយ ក៏គេឲ្យលើកទាំងយប់ទាំងថ្ងៃក៏មានដែរ ។ ដោយមនុស្ស

ដោយកន្លែងដូចថាយើងធ្វើ ខុសអី គេដាក់ពិន័យយើង។ ពិន័យទៅ គេឲ្យលើកទាំងយប់ទាំងថ្ងៃក៏មានដែរ។

ធានី : មីងឃើញដែរ?

សុផល : មាន បើថាដូចថាយើងអ្នកមិនដែលនេះ មិនអីទេ បើថាអ្នកណា ដូចថាយើងមានករណី យើងខូចដីង បានយើងធ្វើចឹង បានគេឲ្យយើងលើកទាំងយប់ទាំងថ្ងៃក៏មាន។

ធានី : មីងស្គាល់ឈ្មោះ អ្នកដែលក្នុងកងករណីនឹងទេ ធ្លាប់មានច្រើន?

សុផល : ធ្លាប់ដើរច្រើន ប៉ុន្មានភ្លេច។

ធានី : ឃើញច្រើន កងករណីធ្វើចឹង?

សុផល : ចា៎! ភ្លេចហើយចុះវាច្រើនឆ្នាំដែរ ទោះបីវាមិនបាន។

ធានី : ចុះពេលដែលមីងធ្វើការនៅទំនប់ត្រពាំងថ្មនឹង មានអ្នកថ្មីយើងទៅធ្វើការជាមួយមីងទេ?

សុផល : មានតើ អ្នកមកពីភ្នំពេញ។

ធានី : អ្នកមកពីភ្នំពេញម៉េង?

សុផល : នោះ មកពីភ្នំពេញ មកពីតាកែវស្អី។

ធានី : មានអ្នកមកពីតាកែវធ្វើដែរ?

សុផល : មាន។

ធានី : មើលទៅសាច់ឈាមគាត់អ្នកគ្រាន់បើដែរ?

សុផល : គេអ្នកមាន សព្វថ្ងៃគេមានមែនទែន ខ្ញុំទៅលេង។

ធានី : គាត់ឈ្មោះអីគេ?

សុផល : ឈ្មោះ ម៉ាលី ប្ដីគេឈ្មោះ កាន ធ្វើស្ដីគេប្រធានក្រុម។

ធានី : ប្រធានក្រុមគេនៅណា?

សុផល : ប្ដីគេធ្វើការអនុក្រុងភ្នំពេញ។

ធានី : ហើយម៉ាលីនឹង អ្នកមកពីតាកែវ?

សុផល : តាកែវ គេតាមប្ដីគេបាស់ រកស៊ីមាន។

ធានី : ចង់និយាយថា ម៉ាលី គាត់នៅតាកែវនឹង គាត់មកពេលណា?

សុផល : ដែលមកនៅនេះ គេជម្លៀសមកទាំងកំប៉េះពេញតែភូមិ គ្រប់តែផ្ទះ។

ធានី : ជម្លៀសមកពេលណា?

សុផល : ជម្លៀសមកសម័យនោះដឹងឆ្នាំណា។

ធានី ៖ ជិតវៀតណាមចូលនៅកាលនឹង?

សុផល ៖ ទេ! ដូចជាមុនៗ

ធានី ៖ មុនពេលណា?

សុផល ៖ មុន មើលយើងទៅចល័តនោះឆ្នាំៗ

ធានី ៖ ចឹងមីងថាទៅលើកត្រពាំងថ្មនឹង មានស្គាល់អ្នកធ្វើការនៅនឹងច្រើនទេ?

សុផល ៖ ត្រពាំងថ្ម ភ្លេចអស់ហើយ ស្គាល់តែមុន ប៉ុនសព្វថ្ងៃភ្លេចហើយ គេភ្លេចឯងៗភ្លេចគេៗ

ធានី ៖ មីងដឹងថាអ្នកណាអ្នកគ្រប់គ្រងនៅអាងត្រពាំងថ្មនឹង?

សុផល ៖ អត់ចាំបានទេ ភ្លេចអស់ៗ

ធានី ៖ ចុះម៉េចបានគេធ្វើអាងត្រពាំងថ្មចឹង?

សុផល ៖ ដឹងម៉េចគេប្រើក៏ធ្វើៗ

ធានី ៖ ចុះការហូបចុកនៅនឹងម៉េចដែរ?

សុផល ៖ ហូប គ្រាន់ចល័តបេះហូបទៅ (មិន)យ៉ាប់ប៉ុន្មានទេៗ

ធានី ៖ ហូបបានអីខ្លះកាលនឹង?

សុផល ៖ ត្រីប្រា ត្រីអីនឹងឯង ត្រីប្រាទឹកប្រហុកៗ

ធានី ៖ មានបាយហូបទេ?

សុផល ៖ ហូបបាយៗ

ធានី ៖ បាយប៉ុន្មានទៅចាន?

សុផល ៖ បាយគេ ដាំតាមក្រុមតាមអីៗ

ធានី ៖ ចឹងមីងដាំបាយខ្លួនឯង?

សុផល ៖ ទេ! គេដាំឲ្យ ខ្ញុំមិនអ្នកដាំទេៗ

ធានី ៖ អ្នកណាគេអ្នកដាំ? ដាំតាមក្រុមយ៉ាងម៉េច?

សុផល ៖ ដាំតាមក្រុមតាមកង មានម៉ាកងគេដាំបាយខ្លះគ្នោតទៅ ដាំគេទៅធ្វើការលើកទំនប់បេះ គេទូលបាយទៅឲ្យយើង ម៉ាចានដែនធំៗ ៗ យើងមិនបានដាំបាយខ្លួនយើងទេ គេដាំបាយឲ្យទេៗ

ធានី ៖ ហើយដាំបាយចូលចានដែកនឹង គេដាក់អីចូលក្នុងចានដែកនឹង?

សុផល ៖ ដាក់បាយៗ

ធានី ៖ ចុះម្ហូប?

សុផល ៖ ម្ហូបគេក៏មានឆ្នាំងមានខ្ទះគេ ទាំងឆ្នាំងធំៗ ។

ធានី ៖ ចឹងមីងហូបឆ្អែតទេ?

សុផល ៖ ហូបមានអី ហូបឆ្អែតតើ ។

ធានី ៖ បាយប៉ុន្មាន គេដួសឲ្យយើងហូប យើងហូបម៉េចឆ្អែត? ហូបបាយគេដួសដាក់ចានឲ្យយើងហូប ឬយើងដួសហូបខ្លួនឯង?

សុផល ៖ ដល់យើងទៅ យើងដួសចាន មានចាន ក៏យើងដួសស៊ីខ្លួនយើង តាមក្រុមទៅ យកសម្ភារៈចាន ក៏បាយទៅ២០-១០នាក់ហូបម៉ាកន្លែង ។

ធានី ៖ យើងដួសហូបខ្លួនឯង មិនចាំបាច់គេដួសឲ្យទេ?

សុផល ៖ នោះហើយ ។

ធានី ៖ ហើយក៏មិនបាច់គេដួសទុក?

សុផល ៖ ទៅបានគេហូប ។

ធានី ៖ មីងបានហូបបាយក្តៅៗទេ?

សុផល ៖ បាន ក្តៅៗ ។

ធានី ៖ ពេលនៅត្រពាំងថ្មនឹង បានហូបបាយក្តៅៗរហូត?

សុផល ៖ ហូប ទៅគេទូលចាំងចានដែកគេលើកទៅមានអ្នកដាំបាយទៅផ្សេង ។

ធានី ៖ ចុះមីងនិយាយថា គ្រួសារមីងក្រោយនេះគាត់ឈ្មោះអីគេ?

សុផល ៖ ប៉ាន់ ឈួង ។

ធានី ៖ តាឈួងនឹង គាត់ត្រូវជាប្រធានកងមីងហើយម៉េច បន្ទាប់ពីតាវ៉ាល់ មីងថាស្គាល់គាត់ដែរ?

សុផល ៖ ស្គាល់ ។

ធានី ៖ ម៉េចបានស្គាល់គាត់?

សុផល ៖ ស្គាល់គេ ដូចថាគេចាត់ចែកឲ្យធ្វើការងារទៅ ឲ្យដាក់ជាមួយតាឈួង ដាក់ទៅឲ្យធ្វើប្រាប់ឲ្យធ្វើត្រង់នេះ វាស់វែងដី ។

ធានី ៖ ចឹងតាឈួងនឹង អ្នកប្រាប់មីងត?

សុផល ៖ ហ្នឹងហើយ ។

ធានី ៖ ប្រាប់មីងថាម៉េចខ្លះទៅ?

សុផល ៖ គេមិនមែនប្រាប់ខ្ញុំទេ គេប្រាប់កូនក្រុមទាំងអស់គ្នា អ្នកធ្វើការទាំងអស់គ្នា ។ ដូចមិនទាន់បានស្គាល់គ្នាណា មិនទាន់បានគ្នាណា តាឈួន ទើបបានស្រុកយើងសព្វថ្ងៃ ។

ធានី ៖ តែកាលនឹងបានស្គាល់គាត់ តាឈួនបន្ទាប់ពីតាវ៉ាល់អីចឹង ដឹងដែរ?

សុផល ៖ អឺ! ស្គាល់ ។

ធានី ៖ គាត់ស្គាល់មីងដែរ?

សុផល ៖ ស្គាល់ៗតិចៗ មិនស្គាល់ដូចដីវី មិនស្គាល់ មិនទាន់ស្គាល់ច្បាស់ដូចសព្វថ្ងៃ ។ អូ!តានេះៗ ធ្វើប្រធានកាលសម័យបដិវត្តមិញ ។

ធានី ៖ មីងដឹងដែរ ។ ហើយគាត់កាចអត់?

សុផល ៖ ទេ! គ្មានកាចណាំ ។

ធានី ៖ ចុះតាវ៉ាល់?

សុផល ៖ អឺ! ដូចជាថាខ្លះថាកាច ខ្លះស្លូតទៅ ។

ធានី ៖ ចុះមីង ចំពោះចិត្តមីងផ្ទាល់ មីងគិតថាតាវ៉ាល់កាចហើយស្លូត?

សុផល ៖ មិនជាកាចប៉ុន្មាន ខ្លះក៏ថាកាចដែរ ដូចបញ្ហា យើងមិនសូវដឹងផ្ទៃក្នុងគេៗប្រើ យើងមិនដឹងរឿង ។

ធានី ៖ ចុះគេប្រើមីង គេប្រើឲ្យធ្វើអីគេ?

សុផល ៖ មានប្រើឲ្យលើកទំនប់ ជីកប្រឡាយនឹងឯង ។

ធានី ៖ លើកទំនប់ម៉េចខ្លះ លើកទំនប់នៅត្រពាំងថ្ម លើកទំនប់យ៉ាងម៉េច ដូចថាការងាររបស់មីងធ្វើជាស្អីគេ នៅនឹងដូចថាលើកទំនប់នឹងលើកយ៉ាងម៉េចអីខ្លះ?

សុផល ៖ លើកទំនប់ លើកដី ធ្វើការងារនៅសម័យនោះ ។

ធានី ៖ ហើយមីងលើកដីលើកខ្លួនឯង?

សុផល ៖ លើកខ្លួនយើងទៅ កាលនោះបង្គីរចបយើងមាន ឲ្យយើងរែកទៅ ។

ធានី ៖ ហើយចឹងមីងមានបង្គីរមួយ ចបមួយទៅ កាប់ដីរែកខ្លួនឯងទៅ?

សុផល ៖ ចាំ! កាប់ទៅ មានដងរែក មានអីរែក ។

ធានី ៖ ហើយបង្គីរប៉ុន្មាន?

សុផល ៖ បង្គីរគេតូចៗល្មមឲ្យយើងរែកបាន ។

ធានី ៖ មិនបង្គីរធំទេ?

សុផល ៖ នោះឯង ។

ធានី : បន្ទីរតូចប៉ុន្មានទៅ អាចជួយប្រាប់ខ្ញុំបាន?

សុផល : ហ៎! បន្ទីរគេប៉ុនៗនេះ បន្ទីរកាលនោះ គេដាក់វែកទៅ។

ធានី : ចុះអ្នកផ្សេងបន្ទីរប៉ុនៗមីងទេ?

សុផល : ដូចតែគ្នាចេះ។

ធានី : ដូចតែគ្នាទាំងអស់គ្នា?

សុផល : ចា៎! ដូចតែគ្នា។

ធានី : ចុះមីងខ្ញុំឮមីងៗខ្លះគាត់និយាយ គាត់ថាបន្ទីរគាត់ធំៗ ហើយលើកអត់ចង់រួចម៉ាបន្ទីរ?

សុផល : ខ្លះចុះឯង ខ្លះលើញបន្ទីរធំទៅ។

ធានី : ហេតុអីបានអ្នកខ្លះបន្ទីរធំ អ្នកខ្លះបន្ទីរតូចចឹង?

សុផល : ចុះគេដាក់ម៉ែត្រគីបឲ្យយើងលើកលឿននោះ យើងចង់បានលើកច្រើន ដូចថាខ្លះលើកបាន រួចដល់៣ម៉ែត្រគីបទៅ។ ខ្លះថាធ្វើទៅមិនរួច កម្លាំងយើងធ្វើទៅមិនដល់ យើងធ្វើតាមនោះឯង។

ធានី : ម៉េចក៏ខុសគ្នាចឹង អ្នកខ្លះប៉ុននឹង អ្នកខ្លះមិនប៉ុននឹង?

សុផល : អានេះគេធ្វើគេរើសយកកម្លាំងអ្នកខ្លាំង អ្នកមិនខ្លាំង អ្នកណាខ្លាំងទៅ។

ធានី : ចុះកម្លាំងមីងគេហៅកម្លាំងអី?

សុផល : កម្លាំងធម្មតាមានអី។

ធានី : បើចឹងដដែលគេចាំបាច់ឲ្យមីងធ្វើនៅទំនប់នឹងធ្វើអី មិនព្រមនៅផ្ទះនៅអីល្អជាង បើយើងអត់សូវមានកម្លាំងមានអីចឹង?

សុផល : សម័យនោះទៅទាំងអស់គ្នា ទៅចេញពីផ្ទះ ទៅនៅដេកនេះរាប់។

ធានី : ទៅនៅដេករាប់ម៉េច?

សុផល : រាប់ឆ្នាំរាប់អីទៅនោះឯង។

ធានី : កាលនឹងមីងសម្រាកនៅកន្លែងណា ពេលនៅត្រពាំងថ្មនឹង?

សុផល : នៅអាងនឹងឯង តែអាងត្រពាំងថ្មគេធ្វើរោងឡើងវែង ចុះមនុស្សរាប់តែរយ មិនមានរាប់តែនេះណា។

ធានី : ដូចថាមីងនៅនឹងហូបចុកអី ចុះទឹកអីផូតបានកន្លែងណាផូត បើកំពុងធ្វើត្រពាំង?

សុផល : មានត្រពាំងថ្មគេ ត្រពាំងគេមាន។

ធានី : មានទឹកហូបអីគ្រប់គ្រាន់ដែរ?

សុផល ៈ មានៗ

ធានី ៈ មានហូបគ្រប់គ្រាន់?

សុផល ៈ ចាំ! មាន វត្តគេៗ

ធានី ៈ វត្តនៅកន្លែងណា?

សុផល ៈ វត្តនៅក្នុងភូមិត្រពាំងថ្មៗ

ធានី ៈ កាលនៅក្នុងទំនប់នឹង កងមីង ហៅកងអីគេ គេមានឈ្មោះកងគេ ដូចថានៅតាមភូមិចឹង គេ មានឈ្មោះកងគេៗ កាលនឹងមីងនៅក្នុងកងអីគេ នៅត្រពាំងថ្មនឹង?

សុផល ៈ កងគេមិនចាំទេ ក្នុងកងគេថាលើកដីក៏លើកទៅៗ

ធានី ៈ ដូចថាកាលនឹងកងគេមានកងកម្លាំងទី១ កម្លាំងទី២ ដូចថាកងតាវ៉ាល់ចឹងវាមានកងពិសេស មួយទៀត មែន?

សុផល ៈ មានកងពិសេសគេៗ

ធានី ៈ ចង់សួរថា មីងនៅក្នុងកងអីគេ កងតាវ៉ាល់ កងពិសេស ឬក៏កងកម្លាំងទី១ ទី២អីចឹង?

សុផល ៈ មិនចាំទេ កងយើងលើកធម្មតា យើងលើកមិនខ្លាំង យើងលើកតាមធម្មតាប៉ុននឹងៗ

ធានី ៈ មានប៉ុន្មានកងៗដូចមីង កាលនឹងគេហៅកងអីគេ? បើសិនជាមីងថាកងធម្មតាចឹង វាគួរតែ មានកងវរៈ កងតំបន់ កងភូមិភាគកងអីចឹងៗ ចុះមីងនៅក្នុងកងអីគេ?

សុផល ៈ អត់ចាំទេ ឈ្មោះអីៗ ៗ

ធានី ៈ អត់ទេ ចង់ថាមីងនៅក្នុងកងអីគេ? នៅក្នុងកងវរៈ កងតំបន់ កងភូមិភាគ ឬកងអីចឹង ដូច នៅក្នុងទំនប់មួយមានតាវ៉ាលមួយប្រធានធំៗ ចឹងមានអាកងពិសេសមួយទៀតរបស់តាវ៉ាល់ គឺកងពិសេសៗ ដូចថាមីងនៅក្នុងកងពិសេសអីទៅ បើមិននៅកងពិសេសរបស់តាវ៉ាល់វាគួរ តែនៅក្នុងកងណាមួយ?

សុផល ៈ កងអីគេ កងធម្មតានឹង មិនដឹងថាកងស្អីទេ អត់ចាំទេៗ ពីមុនវាភ្លេចអស់ទៅហើយ វាធ្វើ ការពិបាកយ៉ាងណា ដល់សព្វថ្ងៃៗ

ធានី ៈ កាលនឹងមីងធ្វើការលំបាកយ៉ាងម៉េច អាជួយប្រាប់គិចបានទេ?

សុផល ៈ ទេ! មានពិបាកៗរឿងលើកដីទៅវាពិបាកៗ

ធានី ៈ លើកដីយ៉ាងម៉េច ពិបាកយ៉ាងម៉េច?

សុផល ៈ លើកដី ខំលើកទៅៗ

ធានី ៖ ចុះបើមីងថាលើកដីមីងថាពិបាក ម៉ាម៉ែត្រគីប ចុះទម្រាំអ្នកដែលគេធ្វើ៣ម៉ែត្រគីប ហើយគេបានហូបដូចមីងដែរអត់ទេ បានហូបបាយ ហូបឆ្អែតអីចឹង បានចឹង?

សុផល ៖ ឆ្អែតៗដូចតែគ្នា ។

ធានី ៖ ហូបដូចគ្នា?

សុផល ៖ និយាយខុសខ្លះៗក៏គ្នាថាហូបមិនឆ្អែត ខ្លះថាហូបឆ្អែត ដឹងថារម៉េច ។

ធានី ៖ ដូចថាកាលមីងហូបឆ្អែតនឹង មីងដួសបាយហូបខ្លួនឯងហូបម៉ាឆ្អែត មីងនិយាយប្រាប់ខ្ញុំមិញចឹង?

សុផល ៖ នោះឯង ។

ធានី ៖ យើងហូបម៉េចហូបទៅ ឲ្យតែយើងហូបឆ្អែត យើងឈប់ហូបទៅ?

សុផល ៖ នោះឯង ។

ធានី ៖ ចឹងបានន័យថាមីងមានកម្លាំង អាចធ្វើការបន្តទៀតបាបស្រួល ។ ចង់សួរថាម៉េចបានមីងខុសពីអ្នកដទៃ អ្នកខ្លះគាត់ថថាហូបអត់ឆ្អែតហើយ ហូបបានបបររាវៗទៀតហើយអត់បាន ដួសបាយហូបខ្លួនឯងចឹងទេ បាយទុកដល់តែរុយរោម?

សុផល ៖ បើនិយាយចឹងវាដោយកន្លែងអារឿងហូប ។

ធានី ៖ ដោយកន្លែងយ៉ាងម៉េចមីង?

សុផល ៖ ដោយកន្លែងខ្លះ គ្នាហូបបបររាវឃ្លោកទៅ មើលដូចខ្ញុំឈប់ចល័តមកនៅជាមួយម៉ែ នៅស្រុក នៅព្រៃមាន់ដែលគេជម្លៀសពីភូមិនេះចេញទៅ ។ ចេញទៅនៅនឹង ក៏បបរខ្ទុះត្នោតហូបមិនឆ្អែត មើលដូចប៉ាខ្ញុំអីស្ទុះតែហើមជើង ហើមដៃអស់ហើយកាលនឹង ។ អានេះដោយកន្លែងៗខ្លះហូបឆ្អែត ខ្លះក៏ហូបមិនឆ្អែត ។

ធានី ៖ ចុះកាលពេលមីងទៅធ្វើនៅទំនប់ត្រពាំងថ្ម មីងមើលទៅឃើញ គេហូបដូចតែមីងដែរឬមួយ ក៏ដោយកន្លែងដូចមីងនិយាយមិញ?

សុផល ៖ ដោយកន្លែងៗខ្លះក៏ហូបមិនឆ្អែតទៅ ខ្លះហូបឆ្អែតទៅ ពូនិយាយដែរខ្លះក៏ហូបមិនឆ្អែតកន្លែង ខ្លះហូបឆ្អែត ។ វាដោយវាខុសកន្លែងខ្លះក៏គឺងតែងខ្លាំង ។

ធានី ៖ ចុះកាលមីងនៅកន្លែងណា អ្នកណាអ្នកមេធំក្រោមតាវ៉ាល់ អ្នកណាគេ?

សុផល ៖ អត់ចាទេ ។

ធានី ៖ ចាំឈ្មោះគាត់អត់?

សុផល ៖ អត់ចាំទេ ភ្លេចឈ្មោះអស់ហើយ ។

ធានី ៖ ទំនប់ត្រពាំងថ្មនៅក្នុងតំបន់អីគេ មីងដឹងទេ?

សុផល ៖ ខ្ញុំអត់ដឹង ដឹងនៅត្រពាំងថ្មដឹងតំបន់អី តំបន់៥ ។

ធានី ៖ ចុះនៅភូមិភាគអី មីងដឹង?

សុផល ៖ អត់ដឹង ។

ធានី ៖ អត់ដឹង តែដឹងនៅតំបន់៥?

សុផល ៖ នោះហើយ ។

ធានី ៖ ចឹងអ្នកណាគេគ្រប់គ្រងតំបន់៥ មីងដឹង?

សុផល ៖ អត់ដឹងទេ ។

ធានី ៖ ចុះមីងស្គាល់យាយចែម?

សុផល ៖ ទេ! ឮតែគេថាយាយចែម មិនដែលឃើញមុខផង ។

ធានី ៖ កាលពេលយាយចែមមកដល់ មីងការនៅ?

សុផល ៖ អត់ដែលឃើញយាយចែមផង ។

ធានី ៖ ប៉ុន្តែចង់និយាយថាពេលយាយចែមមកដល់ ឮឈ្មោះគាត់នឹង ពេលនឹងមីងការនៅ?

សុផល ៖ ការហើយ ។

ធានី ៖ ឮឈ្មោះយាយចែម ឮថាម៉េច?

សុផល ៖ គ្រាន់ថាឈ្មោះយាយចែមៗ ។

ធានី ៖ គាត់ជាអ្នកណា?

សុផល ៖ ខ្ញុំអត់ដឹង ។

ធានី ៖ ចុះគេហៅឈ្មោះគាត់ធ្វើអីចុះ បើគេអត់ស្គាល់គាត់?

សុផល ៖ ចុះគេហៅឮតែឈ្មោះយាយចែម ធ្វើការឯណាដូចមិនដែលនៅចល័តនៅណា នៅអន្លង់វែង នៅណាផ្សេង មិនដឹងយាយចែមៗ ។

ធានី ៖ យាយចែមនៅអន្លង់វែង?

សុផល ៖ នៅណាផ្សេង ដឹងកន្លែងនៅណា ។

ធានី ៖ អត់ដឹងនៅណាទេ ចុះម៉េចបានគាត់មកកងចល័តនឹងធ្វើអី?

សុផល ៖ មកកងចល័ត មិនដែលឃើញគាត់គ្រាន់តែឮតែឈ្មោះ ដឹងតែគេថាយាយចែមៗ ។

ធានី ៖ គ្រាន់គេថា អត់ដឹងថាយាយចែមនឹងជាអ្នកណាទេ?

សុផល ៖ នោះហើយ ។

ធានី ៖ ចុះក្រៅពីឈ្មោះយាយថែម មានពុឈ្មោះអ្នកណាផ្សេងទៀតដែលគេហៅ?

សុផល ៖ អត់ ។

ធានី ៖ ដែលមីងបានពុ?

សុផល ៖ អត់ ។

ធានី ៖ ពុតែឈ្មោះយាយថែមមួយ? ចុះមីងនៅកងចល័តត្រពាំងថ្មនឹង យ៉ាងម៉េចដែរ ដូចថាការគ្រប់គ្រងរបស់គេយ៉ាងម៉េចដែរ គេធ្វើយ៉ាងម៉េចខ្លះ គេដាក់ទិសការងារអីយ៉ាងម៉េច?

សុផល ៖ អត់ចាំស្អី អត់ស្គាល់ទៅចល័តជាមួយគ្នាអស់ស្គាល់ ។

ធានី ៖ ចឹងមីងថាមីងរៀបគ្រួសារនៅឆ្នាំ៧៧ រៀបគ្រួសារជាមួយគាត់ឈ្មោះអីគេ?

សុផល ៖ ឈ្មោះ គុណ ។

ធានី ៖ គាត់ជាអ្នកណាគេ?

សុផល ៖ ចល័តទាំងអស់គ្នានឹង ចល័តជាមួយគ្នានៅភូមិនេះ តែងរាប់ហើយ រត់បាត់សម័យបដិវត្តរត់ ។

ធានី ៖ តែគុណនឹង គាត់ស្នើមីងឲ្យរៀបការឬយ៉ាងម៉េច?

សុផល ៖ ស្នើគ្នារៀបការ ។

ធានី ៖ និយាយទៅមីងពេញចិត្តគាត់ដែរ គាត់ពេញចិត្តមីងដែរ បានស្នើឲ្យទៅរៀបការ?

សុផល ៖ គេស្នើទៅក៏រៀបទៅៗក៏នាំគ្នាមកនៅភូមិ ។

ធានី ៖ ពេលរៀបការនឹង អ្នកណាគេចូលរួមក្នុងពិធីការនឹងខ្លះ?

សុផល ៖ អឺ! កាលនោះច្រើន ភ្លេចអស់ហើយច្រើនគូ រាប់មិនដឹងប៉ុន្មានគូទេ គ្រាន់តែដូចថាយើងការម៉ាខ្សែ ខ្ញុំភ្លេចហើយ យូរគ្រាន់ ។

ធានី ៖ មីងរកនឹកមើលមីងការប៉ុន្មានគូ?

សុផល ៖ ច្រើនគូ គេតំរៀបជួរគ្នាការ ដឹងថាប៉ុន្មាន ។

ធានី ៖ ហើយអ្នកណាគេចូលរួមក្នុងពីធីការនឹង?

សុផល ៖ ច្រើនចល័តទាំងអស់គ្នា ។

ធានី ៖ ចង់និយាយថា អ្នកណាគេមេធំ ដែលគាត់ចូលរួមក្នុងពិធីការ ដូចថាបើកវគ្គប្តេជ្ញាម៉េចខ្លះអីខ្លះ ដូចថាមីងចាប់ដៃគូជាមួយអ្នកណាគេៗអ្នកប្រាប់?

សុផល ៖ យូរមិនបានចាំ មិនបានសួរមិនបានអី គ្រាន់តែដឹងថាគ្នាច្រើន ។

ធានី ៖ ចង់និយាយថា ចុះក្នុងពិធីការនឹងគេធ្វើម៉េចខ្លះមីងដឹង? ម៉េចបានមីងដឹងថាមីងការ?

សុផល ៖ គេហៅទៅអង្គុយតំរៀបជួរ ក៏ខ្លះឲ្យការទៅ គេការឲ្យ ។

ធានី ៖ ហើយការនឹងគេធ្វើម៉េចខ្លះ គេការឲ្យនឹង?

សុផល ៖ ការនឹងដូចថាគេប្រជុំប្រកាសប្រាប់ទៅ មិត្តគេនោះ មិត្តយើងនេះ ។

ធានី ៖ អ្នកណាគេអ្នកប្រាប់មីង?

សុផល ៖ ខ្ញុំភ្លេចទៅ វាយូរណាស់ មិនបានចាំ ។

ធានី ៖ ដល់ពេលការហើយធ្វើម៉េចទៀត ការហើយមីងទៅណាទៀត?

សុផល ៖ ការរួចហើយនាំគ្នាមកនៅផ្ទះវិញទៅ សុំគេមកនៅភូមិវិញ ។

ធានី ៖ នៅភូមិណា កាលនឹងមីងនៅ?

សុផល ៖ នៅមុនដំបូង មកដល់ភូមិគោកចក្រី ចេញពីគោកចក្រីមក បានមកនៅភូមិដូនជ្រែង ។

ធានី ៖ ចឹងកាលពេលមីងការនៅត្រពាំងថ្ម ឬការនៅណា?

សុផល ៖ ត្រពាំងថ្ម ។

ធានី ៖ ការនៅក្នុងទំនប់នឹងម៉ង?

សុផល ៖ នឹងទំនប់ ។

ធានី ៖ នៅលើទំនប់ លើខ្នងទំនប់ ឬក្នុងទំនប់?

សុផល ៖ ទេ! ខាងអែបរោងការ អែបនឹងផ្លូវលើទំនប់ ។

ធានី ៖ ចឹងមីងដឹងថាទំនប់នឹងមានប្រវែងប៉ុន្មានម៉ែត្រ?

សុផល ៖ នោះឯងមិនដឹងទេ ទំនប់នោះធំណាស់ មិនដឹងថាប៉ុន្មានទេ ។

ធានី ៖ ហើយវាខ្ពស់អត់?

សុផល ៖ ខ្ពស់ ។

ធានី ៖ ខ្ពស់ប៉ុន្មានទៅ?

សុផល ៖ មិនដឹងទេ ។

ធានី ៖ កាលពេលមុនពេលមីងការនឹង គេសម្ពោធន៍ទំនប់នឹងនៅ?

សុផល ៖ កាលខ្ញុំបានប្តីរួចមុន មិនទាន់រួចទេ ទំនប់គេនៅតែធ្វើទាល់តែទៀត ។

ធានី ៖ ចឹងអត់ទាន់មានសម្ពោធន៍មានអីទេ?

សុផល ៖ អត់ទេ ។

ធានី ៖ ចុះកាលពេលមីងនៅនឹង គេមានដាក់ល្ខោន ដាក់អីឲ្យយើងមើល ពេលបញ្ចាំងកុនអីមានទេ កាលនៅលើកទំនប់ត្រពាំងថ្ម?

សុផល ៖ ដូចមិនមាន ។

ធានី ៖ ចុះគ្រួសារមីង អ្នកស្រុកនៅណាវិញ?

សុផល ៖ នៅព្រះនេត្រព្រះ ។

ធានី ៖ ភូមិព្រះនេត្រព្រះ?

សុផល ៖ នោះហើយ ។

ធានី ៖ ពេលមីងត្រឡប់មកដូនជ្រែង ពេលនឹងមីងធ្វើអី?

សុផល ៖ អូ! គ្រួសារសម័យបដិវត្ត អ្នកភូមិដូនជ្រែង ។

ធានី ៖ ចឹងដល់ពេលមីងរៀបការហើយ មីងមិនថាមីងត្រឡប់មកនៅភូមិយើងវិញ ភូមិដូនជ្រែង ហើយមីងធ្វើអីគេ ពេលមកដល់ភូមិដូនជ្រែន?

សុផល ៖ អត់មានធ្វើអីទេ កាលនោះនៅមើលកូនឲ្យគេ ដូចថាយើងទំនងនំដែរ យើងមើលកូនឲ្យគេ ។

ធានី ៖ យ៉ាងម៉េចទៅ?

សុផល ៖ មានស្អី មើលតែកូនឲ្យគេទៅ ម៉ែគេទៅធ្វើការទៅ យើងមើលកូនឲ្យគេ ។

ធានី ៖ រហូតដល់ពេលណាទៅ ដែលវៀតណាមចូលមក? ពេលនឹងមីងសម្រាកកូននៅ?

សុផល ៖ ដល់វៀតណាមចូលមក កូនបានកន្លះខែ ។

ធានី ៖ មីងសម្រាលហើយ ហើយមីងនៅភូមិនឹងទៅ?

សុផល ៖ ចា៎!

ធានី ៖ ចុះគ្រួសារមីងទៅណា?

សុផល ៖ រត់ៗទៅក៏ងាប់ ។

ធានី ៖ ចុះម៉េចបានរត់?

សុផល ៖ រត់កាលនោះខ្លាច ។

ធានី ៖ ខ្លាចអីគេ ចុះម៉េចបោះបង់មីងចោល នៅតែឯង?

សុផល ៖ បើនិយាយយ៉ាប់បានប្តី តែអត់ត្រូវគ្នាទេ បានទៅគេទៅនៅម៉ែគេទៅ ខ្ញុំនៅម៉ែខ្ញុំទៅ ខ្ញុំមិនចង់និយាយ ។ រឿងទៅក៏បែកគ្នា ប្តីគេរត់ ដូចថាខ្លាចកាលនោះសម័យនោះ ប្តីខ្ញុំកូនសិស្សសាលា រៀនខ្ពស់ទៅ ដូចថាកាលនោះឲ្យតែអ្នកណារៀនធំ ដឹងតែពីខ្លាច ហ៊ាននៅ ។ ខ្លាចសម្លាប់ចោល រត់ឆ្លងទៅ វេទនា ។

ធានី ៖ ម៉េចមីង ខ្លាចរត់ទៅខាងណា?

សុផល ៖ រត់ទៅ ដឹងគេរត់ទៅខាងណាទេ គេនៅផ្សេង គេទៅនៅខាងម៉ែគេ ដល់បានគ្នាទៅមិនត្រូវគ្នាទេ គេទៅនៅម៉ែទេ ខ្ញុំទៅនៅម៉ែខ្ញុំ ដល់ពេលគេរត់ៗទៅ ។

ធានី ៖ ចឹងមីងបានកូនហើយ បានគាត់រត់ទៅចោលមីង?

សុផល ៖ កាលនោះមិនត្រូវគ្នា ដូចថាអ្នកស្រុកថាយើងដូចថាខ្មាចសាបរៀងខ្លួន ខ្មាចសាបទៅគេហៅទៅនៅជាមួយគ្នាវិញ នៅបានទំងន់ៗក៏បែកគ្នាទៅ ។ គេទៅនៅជាមួយម៉ែគេទៅ ម៉ែដូចថាដឹងដំណឹងមិនសូវត្រូវគ្នាហើយ បើសិនជាសាប់មួយឈ្មោះគ្នា កាលនោះខ្មាចគេវៃចោល ក៏ទៅនៅ គេឲ្យចល័តទៅនៅណា អារក្សបាក់-ក ប្ដីនោះ ទៅនៅផ្សេង ឲ្យចល័តទៅនៅផ្សេងតែម្ដង ខំឈ្មោះគ្នាដឹងថាសាប់ ។ ដល់នេះទៅនៅជាមួយម៉ែគេ ដល់ទៅនេះគេខ្មាចគេរត់ទៅបាត់រហូត ។

ធានី ៖ ហើយមីង កូននឹងកូនស្រី កូនប្រុស?

សុផល ៖ កូនប្រុស ។

ធានី ៖ រាល់ថ្ងៃគាត់នៅរស់ទេ?

សុផល ៖ ឪមីងនេះឯង រស់ទៅធ្វើស្រែអាងសាលា ។

ធានី ៖ ហើយចឹងបានកូនប្រុសមួយ?

សុផល ៖ ចាំ!

ធានី ៖ ចុះពេលណាបានស្គាល់ពូប៉ាន់ ឈួង?

សុផល ៖ តាឈួងនេះ ដល់កូនខ្ញុំបាន៥ឆ្នាំ បានតាឈួង ។

ធានី ៖ ម៉េចបានស្គាល់គាត់ បានជួបគាត់ម្ដងទៀត?

សុផល ៖ តាឈួងនេះ ដូចថាចុះស្រុកគាត់នៅព្រះនេត្រព្រះយើងពេលបុណ្យទានទៅ យើងទៅឃើញ ។

ធានី ៖ ចឹងប៉ាន់ ឈួងនឹង គាត់នៅស្រុកដែរ គាត់អត់ទៅណាទេ?

សុផល ៖ នោះហើយ គាត់បានប្រពន្ធគាត់នៅនេះ ។

ធានី ៖ គាត់មានប្រពន្ធដែរ តែគាត់?

សុផល ៖ មានប្រពន្ធ តែគាត់អត់មានកូនទៅ ក៏គេមានប្ដី ។

ធានី ៖ យកទៀត អត់ទៀត?

សុផល ៖ យកទៀតអត់ ។

ធានី ៖ រាល់ថ្ងៃគាត់មកនៅនេះ ចឹងប្រពន្ធគាត់នៅនោះដដែល?

សុផល :  ប្រពន្ធនោះនៅព្រះនេត្រព្រះ ។

ធានី :  ចឹងមីងរៀបការជាមួយគាត់ឆ្នាំប៉ុន្មាន មីងចាំ ។ អូ!មែន កូនមីងបាន៥ឆ្នាំ ចឹងអាច៨៤ ៨៥?

សុផល :  និយាយខ្ញុំនឹងគាឈ្មួង ដូចមិនដល់៨៥ទេ ៨២ ៨៣ ។

ធានី :  ចឹងមីងដូចថារៀបការអីធម្មតាដូចនៅស្រុកភូមិយើងទៅ?

សុផល :  ដែលការក្រោយនេះ បានសែន ។

ធានី :  ចឹងមីងកាលសម័យខ្មែរក្រហម ដែលមីងរៀបការ មីងអត់ស្រឡាញ់គាត់ទេ?

សុផល :  ប្ដីមុននោះ កាលនោះដូចថាយើងគេឲ្យយក យើងចេះតែយកដូចថាមិនទាន់ដឹងថាស្រឡាញ់យ៉ាងណា កាលនោះល្ងង់ និយាយឲ្យអស់ ។ យកទៅក៏នៅទៅដូចមិនត្រូវគ្នា គេទៅណាទៅៗយើងទៅតាមយើង គេទៅតាមគេ ។

ធានី :  តែ គុណ នឹង គាត់មានមុខងារធ្វើអីគេ បានអាចស្នើមីងបានចឹង?

សុផល :  ប្ដីនឹង ធ្វើការកងចល័តជាមួយគ្នានឹងឯង លើកទំនប់ លើកប្រឡាយជាមួយគ្នា ។

ធានី :  គាត់ស្នើខ្លួនឯង ឬក៏គេចាត់តាំងឲ្យមីងការជាមួយតែម្ដង?

សុផល :  ទេ! ដូចថាដឹងម៉ែឪថាគ្រួសារសំងំ ចេះតែឲ្យយកទៅណា ដល់ពេលយកទៅ ។

ធានី :  ម៉េចបានអត់ត្រូវគ្នាចឹង?

សុផល :  កាលនោះដូចថា ដល់មកដល់ភូមិចឹង ប្ដីខ្ញុំគេរៀនៗគេមានពួកម៉ាក់គេ ដូចមនុស្សស្រី ពួកម៉ាក់គេស្អាតណាស់ ស្រឡាញ់គ្នាដូចប្ដីប្រពន្ធ ។

ធានី :  តែប្រុស ឬស្រី?

សុផល :  ប្រុស ស្រឡាញ់គ្នាដូចប្ដីប្រពន្ធ ដូចថាសុខចិត្តចោលប្រពន្ធ មិនចោលពួកម៉ាក់ រត់ទៅងាប់ទាំង២នាក់ទៅ ។

ធានី :  មិនមែនគាត់ចូលចិត្តប្រុសដូចគ្នា?

សុផល :  គេធ្លាប់រៀនជាមួយគ្នាកាលពីសង្គមមិញ ។ បើសិនជាប្ដីខ្ញុំនៅចូលសម័យនេះបើមិនធ្វើអីៗ បើមិនធ្វើពេទ្យ ឬមួយគ្រូបង្រៀននេះឯងចុះបើគេរៀនឡើងចប់ ។

ធានី :  គាត់ខ្លាចគាត់រត់ទៅ?

សុផល :  គាត់រត់ ។

ធានី :  តែគាត់រត់នឹង វៀតណាមអត់ទាន់ចូលមកទេ?

សុផល ៖ អត់ទាន់ចូលទេ មុនៗមិនយូរទេ មុនប្រហែល២-៣ខែមុននឹងឯង រត់ទៅ គាត់ងាប់អាចុង ជិតចប់ហើយ ។

ធានី ៖ ដឹងគាត់ឈ្មោះពេញឈ្មោះអីទេ គុណនឹង?

សុផល ៖ ឪ ពៅ ប្តីខ្ញុំ ។

ធានី ៖ ឪពុកខាងគ្រួសារមីងមុននឹង?

សុផល ៖ ឈ្មោះ តាពៅ ដល់តាគេមិនស្គាល់ទេ ។ តែខ្ញុំក៏មិនបានទៅសួរអី ។

ធានី ៖ តែគាត់រស់នៅរាល់ថ្ងៃ បងប្អូនសាច់ញាតិខាងគ្រួសារមីងចាស់?

សុផល ៖ នៅភូមិនេះ នៅសព្វថ្ងៃ ។

ធានី ៖ មីងដែលធ្លាប់ឮរឿងតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទេ?

សុផល ៖ អត់ដឹង ។

ធានី ៖ចេះមីងរាល់ថ្ងៃនៅភ្នំពេញយើងនឹ មានតុលាការមួយ ហើយគេបង្កើតតុលាការនឹង ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៅសម័យខ្មែរក្រហម គេកាត់ទោសនឹង គឺដើម្បីដាក់ទោសអ្នកដែលមេដឹកនាំជាន់ខ្ពស់ទាំងអស់នឹង ដែលគាត់បានដូចថាបង្កើតរបបនឹងឡើងហើយ បង្កឲ្យប្រជាជនយើង ដូចមីងនិយាយថា មីងត្រូវរែកដី លើកទំនប់ ជីកប្រឡាយ ហើយត្រូវរៀបការ អត់ពេញចិត្តចង់ការ តែបើយើងត្រូវឲ្យការយើងត្រូវការ បើយើងអត់ការយើងខ្លាចស្លាប់ ។ ចឹងគេកាត់ទោសពួកគាត់នឹងឯង ព្រោះពួកគាត់អ្នកបណ្តោយឲ្យមានរបបនឹង ដូចថាអត់មានសិទ្ធិ កម្មសិទ្ធិអីទាំងអស់ ។ អស់រលីង ហើយចឹងគេកាត់ទោសគាត់ហើយនឹងមានប្រជាជនមួយចំនួនដូចមីងប្រាប់ចឹងថា អត់បាយ អ្នកខ្លះទៅស្លាប់ដោយសារអត់បាយ ខ្លះទៅស្លាប់គេសម្លាប់ចោល ដូចគ្រួសារមីងថាខ្លាចគេសម្លាប់ចោលអីចឹង ។ រាល់ ថ្ងៃនឹង គេបានកាត់ទោសមនុស្សម្នាក់ហើយ គាត់នឹងឈ្មោះឌុច គាត់នឹងជាអតីតប្រធានគុក ទួលស្លែង ហើយគេកាត់ទោសគាត់ហើយ ។ គ្រាន់តែគេចាំសេចក្តីសម្រេចចុងក្រោយ ដែលគេបញ្ជាក់ថាគាត់ពិតជាមានទោសពិតមែនបានគេបញ្ជូនគាត់ទៅដាក់គុក ឥឡូវនេះគេអត់ទាន់ដាក់គុកទេ ។ គ្រាន់គេនៅរង់ចាំសេចក្តីសម្រេចចុងក្រោយពីតុលាការនេះ ។ ហើយនៅដល់៤រូបទៀត ដែលគាត់នឹងត្រូវគេយកមកកាត់ទោសដែរ ។ ឥឡូវនឹងគេកំពុងបន្តៗទៀត ។ មីងដែលធ្លាប់ឮឈ្មោះពួកគាត់អត់ទេដូចជា អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ, នួន ជា, មីងដែលឮឈ្មោះពួកគាត់?

សុផល ៖ ធ្លាប់ឮក្នុងទូរទស្សន៍ ។

ធានី ៖ ចឹងមីងធ្លាប់បានតាមដានដែរ?

សុផល ៖ មើលមួយភ្លែត ។

ធានី ៖ ធ្លាប់ឃើញមុខគាត់ផ្ទាល់ កាលពេលមើលក្នុងទូរទស្សន៍នឹង?

សុផល ៖ មិនទាន់ស្គាល់ច្បាស់ទេ ។

ធានី ៖ ពួកគាត់ទាំង៤នាក់នឹង គឺត្រូវគេយកមកកាត់ទោសដែរ ព្រោះគាត់ជាមេដឹកនាំជាន់ខ្ពស់ ។ ដូច ជា អៀង សារីចឹង គាត់ជារដ្ឋមន្ត្រីក្រសួងការបរទេស, អៀង ធីរិទ្ធ គាត់ជាប្រពន្ធរបស់ អៀង សារី ហើយគាត់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចខាងថ្នាំពេទ្យខាងអីចឹង ។ ហើយមួយ ទៀតគឺ នួន ជា គាត់ជាប្រធានរដ្ឋសភា, ខៀវ សំផន គាត់ជាប្រមុខរដ្ឋ កាលសម័យខ្មែរ ក្រហម ។ ហើយអ្នកទាំង៤នាក់ត្រូវគេយកមកចាប់កាត់ទោសបន្តទៀត ។ មីងយល់ថា ការកាត់ទោសអស់នឹងមានប្រយោជន៍អត់សម្រាប់មីង ។

សុផល ៖ (ស្តាប់មិនបាន)

ធានី ៖ ចុះមីងយល់ថាតើយើងគួរតែបង្កើតតុលាការដើម្បីកាត់ទោសអ្នកទាំងអស់នឹង?

សុផល ៖ ថាម៉េចទេ ស្រេចតែគេ ។

ធានី ៖ ចឹងមីងមានអីចង់សួរខ្ញុំវិញ?

សុផល ៖ គ្មានទេ សួរថាម៉េច ។

ធានី ៖ មីងមានសំណូមពរអីម៉េចទេ ឆ្ងល់អី កាត់ទោសកាត់អី ឬក៏ចង់សួរពីអីដេញដោល ។

សុផល ៖ អត់ដឹងឆ្ងល់ថាម៉េចទេ អត់ដឹងរឿងគេ ។

ធានី ៖ អត់ដឹងរឿង?

សុផល ៖ ចា៎! តាមតែគេធ្វើអីធ្វើទៅ ។

ធានី ៖ មិញមីងមានឈ្មោះអីដែរ?

សុផល ៖ ឈ្មោះ ទុយ សុផល ។

ធានី ៖ ឆ្នាំនឹងមីងអាយុប៉ុន្មានហើយ?

សុផល ៖ អាយុ៥១ ។

ធានី ៖ មីងរស់នៅភូមិឃុំណាដែរ រាល់ថ្ងៃ?

សុផល ៖ ភូមិដូនជ្រែង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ស្រុកកំណើតមីងនៅណាដែរ?

សុផល ៖ នៅភូមិដូនជ្រែង ។

ធានី ៖ ឪពុកមីងឈ្មោះអី?

សុផល ៖ ឈ្មោះ គឹម ទី ។

ធានី ៖ គាត់នៅរស់?

សុផល ៖ រស់ ។

ធានី ៖ រស់នៅណាវិញ?

សុផល ៖ នេះនៅនេះ ។

ធានី ៖ នៅភូមិដូនជ្រែងនឹងដែរ?

សុផល ៖ ចា៎! ដូនជ្រែង ។

ធានី ៖ ចុះម្ដាយមីង?

សុផល ៖ ម្ដាយនេះមក ។

ធានី ៖ ឈ្មោះអីគេ?

សុផល ៖ ឈ្មោះ ចាន់ អាត ។

ធានី ៖ គាត់នៅរស់ភូមិយើងដែរ?

សុផល ៖ នឹង ។

ធានី ៖ មីងមានបងប្អូនប៉ុន្មាននាក់?

សុផល ៖ មានបងប្អូន៤នាក់ តែងាប់អស់មួយនៅ៣ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សុផល ៖ ស្រី៣ ប្រុស១ ។

ធានី ៖ ហើយស្លាប់មួយណា?

សុផល ៖ ស្លាប់ប្អូនពៅគេ ឈ្មោះរ៉ារី ។

ធានី ៖ ស្រីដែរ?

សុផល ៖ ស្រី ។

ធានី ៖ ស្លាប់ដោយសារអី?

សុផល ៖ ស្លាប់ជម្ងឺ ។

ធានី ៖ ឈឺពេលណា?

សុផល ៖ ប៉ុន្មានឆ្នាំហើយទេ ភ្លេចហើយ ។

ធានី ៖ ស្លាប់ឥឡូវៗទេ ឬក៏យូរហើយ?

សុផល ៖ នៅឆ្នាំឥឡូវៗនឹងដែរ ស្លាប់៦-៧ឆ្នាំដឹង ឆាប់មឹងមួយនោះ យកអាកូនវាមកចិញ្ចឹមដល់ធំហើយអាយុ១២ ។

ធានី ៖ មឹងរៀនសូត្រដល់ណាទេ កាលពីមុន?

សុផល ៖ រៀនសម័យពីសង្គមមិញ រៀនថ្នាក់ទី១០ ។

ធានី ៖ ចេះអាន?

សុផល ៖ គ្រាន់តែអានអក្សរដាច់នោះឯង ។

ធានី ៖ ថ្នាក់ទី១០ចាស់ នៅសាលាណា?

សុផល ៖ ភូមិដូនជ្រែង ។

ធានី ៖ មឹងដឹងថាហេតុអីបានគេដាក់ឈ្មោះភូមិនឹង ភូមិដូនជ្រែង?

សុផល ៖ ដឹងម៉េចបានគេដាក់ភូមិដូនជ្រែង មិនសូវដឹងពីសម័យមុន ។

ធានី ៖ ចុះកាលពីសម័យខ្មែរក្រហម ភូមិដូនជ្រែងជាភូមិមានមនុស្សនៅអត់?

សុផល ៖ មាន ។

ធានី ៖ ចុះមឹងគេថាគេជម្លៀសមឹងចេញ?

សុផល ៖ ជម្លៀសនៅទៅៗដល់នេះគេជម្លៀសចេញ ។ ជម្លៀសចេញទៅអត់មានទេ ។

ធានី ៖ ភូមិនឹងគេទុកធ្វើអីបើគេជម្លៀសចេញអស់?

សុផល ៖ ចាំ! ស្ងាត់ជ្រាបទៅ ស្ងាត់ទៅមានទៅអីចោលផ្ទះចោលសម្បែងទៅ ។

ធានី ៖ ចុះវត្តយើងមានយូរហើយ?

សុផល ៖ វត្តដូនជ្រែងមាន ។

ធានី ៖ ចុះដល់ពេលសម័យនឹង គេយកធ្វើអីទៅ?

សុផល ៖ ខ្ញុំចល័តដែរ សម័យនោះអត់ដឹងគេធ្វើអីទេ ។

ធានី ៖ អត់ដឹង?

សុផល ៖ នោះ ។

ធានី ៖ អត់ដឹងគណៈសហករណ៍នៅភូមិដូនជ្រែងឈ្មោះអី?

សុផល ៖ ប្រធានសហករណ៍ភូមិដូនជ្រែង ដឹងឈ្មោះតាអី មិនសូវដឹង ខ្ញុំចេញទៅ ។ គ្រាន់តែដឹងថាឪក្មេកខ្ញុំនឹង គាត់ប្រធានភូមិដូនជ្រែង បើសហករណ៍ដឹងតាក្រក់ តាណា មិនសូវដឹងរឿង ។

ធានី ៖ ឪក្មេករបស់មីងឈ្មោះអីគេ?

សុផល ៖ ឈ្មោះតាពៅ ។

ធានី ៖ ឪក្មេករបស់មីងនៅរស់ទេ?

សុផល ៖ អត់ទេ ស្លាប់ហើយ ។

ធានី ៖ ឪក្មេកដែលជាឪគ្រួសារមីងមុននឹង?

សុផល ៖ គ្រួសារមុន តានឹងក៏គេយកសម្លាប់ចោលដែរ ។

ធានី ៖ ចុះម៉េចក៏គ្រួសារមីងភ័យខ្លាច ព្រោះគាត់?

សុផល ៖ ដល់សម័យធ្វើប្រធានភូមិ ពេលនេះទៅគេជម្លៀសទៅព្រៃមាន់ ជម្លៀសទៅប្រធានភូមិក៏គេ នៅតែយកទៅសម្លាប់ចោល ប្រធានភូមិសម័យបដិវត្តក៏គេយកសម្លាប់ដែរ ។

ធានី ៖ ហើយអ្នកណាគេអ្នកសម្លាប់មីងដឹងទេ?

សុផល ៖ អត់ដឹងទេ ។

ធានី ៖ មីងហូបស្រួលជាមួយគ្រួសារមីងទេ អត់អីទេ ។ ចង់និយាយថាព្រោះមីងហូបបាយ ហូបអីចឹង?

សុផល ៖ នៅដែលនៅចល័តយើងមកនៅភូមិយើងវិញនោះ ។ នៅភូមិវិញ គ្មានហូបបាយណា ហូបបបរតើ ហូបបបរឡើងរាវ ចែកគ្នា ប៉ាខ្ញុំឡើងគាត់ចង់ដួលហើយនឹង បើបដិវត្តចូលមកត្រូវ ។

ធានី ៖ ឪពុកបង្កើតមីង?

សុផល ៖ ហ្នឹងហើយ ។

ធានី ៖ ចុះក្រែងមីងមានឪពុកក្មេក គាត់អត់អាចជួយមីងបានទេ?

សុផល ៖ ទេ! ឪពុកក្មេកនៅផ្សេង នៅខាងគេនោះផ្សេង ។

ធានី ៖ ចឹងឪពុកក្មេកមីងជម្លៀសចេញពីភូមិដូនជ្រេងដែរ?

សុផល ៖ អឺ! ចេញគេឲ្យចេញទៅនៅព្រៃមាន់ ដល់ប៉ាខ្ញុំគេឲ្យនៅភូមិរហាល ភូមិផ្តៅ គេឲ្យធ្វើចំការ១ ខ្ញុំនៅជាមួយគាត់ ។ ដូចថាកាលនោះ ប្តីខ្ញុំគេមិនទៅនៅខាងឪ១ក្មេកខ្ញុំគេនៅខាងព្រៃមាន់ ខ្ញុំនៅរហាលនេះ កាលនោះនៅភូមិ....។

ធានី ៖ ចុះម៉េចមីងដឹងថាគ្រួសារមុន ម៉េចបានដឹងគាត់ស្លាប់?

សុផល ៖ បាត់ទៅ មានអី ។

ធានី ៖ មីងសុើបសួរដែរ?

សុផល ៖ ប៉ុន្មានថ្ងៃនេះ ពូបងនិយាយថាងាប់ត្រង់នេះ ។

ធានី ៖ ម៉េចបានគាត់ស្លាប់នៅនឹង?

សុផល ៖ ថាឆ្លងទៅដីថៃ ថាឆ្លងចង់ចេញពីស្រុកខ្មែរយើងទៅៗ គេស្ទាក់ទៅគេវ៉ៃចោល ។

ធានី ៖ អ្នកណាអ្នកប្រាប់មីង ឈ្មោះអីគេ?

សុផល ៖ នេះតា ឈ្មោះបងណាងៗ បងគេបង្កើត ។

ធានី ៖ ហើយគាត់ស្លាប់នៅណា?

សុផល ៖ ដឹងត្រង់ណា ។

ធានី ៖ ចឹងដូចជាអស់អីសួរមីងហើយ ។ ចឹងអរគុណច្រើនមីង ។

សុផល ៖ ចា៎!

«ចប់»